ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០៣/២១.០១.២០២១
សំណុំរឿងជំនុំជម្រះ
លេខ ៤៨៧/០៥.០៥.២០២២
សាលក្រមព្រហ្មទណ្ឌ
លេខ ៥៨៥ ណ/២១.០៦.២០២២

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ ។

សមាសភាពជំនុំជម្រះ

- លោកស្រី [redacted] ជាចៅក្រមជំនុំជម្រះ

តំណាងអយ្យការ

- លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

- លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៣ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ដែលមានដូចខាងក្រោម:

ជនជាប់ចោទ

១.ឈ្មោះ [redacted] ពិសិត ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអ្នករត់កង់បី ទីកន្លែងកំណើតនៅ [redacted] ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជា (រ) ម្តាយឈ្មោះ [redacted] ណុល (រ) ប្រពន្ធឈ្មោះ [redacted] សុឃឿន មានកូន០១ នាក់ កម្រិតវប្បធម៌ថ្នាក់ទី០៧ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥៥/០២២ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០២២

ជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិផ្តៅស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

២.ឈ្មោះ [redacted] សុឃឿន ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត [redacted] ខេត្តសៀមរាប

អាសយដ្ឋានបច្ចុប្បន្នផ្ទះជួល ភូមិទក្សិណខាងត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្ត សៀមរាប ឪពុកឈ្មោះ [redacted] ប៉ោះ (ស) ម្តាយឈ្មោះ [redacted] ភួន (រ) ប្តីឈ្មោះ [redacted] ពិសិត មានកូន០១នាក់ ជានីតិជន ។ (គេចខ្លួន)

ដីកាបង្គាប់ឱ្យនាំខ្លួនលេខ ១២៣ ត.ព្រ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២

ជាប់ចោទពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៩៩** និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

ជើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] សាម៉ែ ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅភូមិវាល ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល ភូមិដាំស្តែ សង្កាត់ស្លាកែត ក្រុងបាត់ដំបង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] សឺន ម្តាយឈ្មោះ [redacted] មុំ ប្តីឈ្មោះ [redacted] ណា មានកូន០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី២ ជានីតិជន ។

<u>អំពីអង្គហេតុ</u>

ជនជាប់ចោទឈ្មោះ [redacted] ពិសិត និងជនរងគ្រោះឈ្មោះ [redacted] សាមៃ បានស្គាល់គ្នាតាមបណ្តាញសង្គមហ្វេសប៊ុក ដោយប្រើអាខោនហ្វេសប៊ុកឈ្មោះ បងវិចត្រគ្រូពេទ្យ បានអះអាងថាខ្លួនជាពេទ្យទាហាននៅភ្នំពេញ។ លុះមកដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ឈ្មោះ [redacted] ពិសិត បានទូរស័ព្ទមកជនរងគ្រោះថាខ្លួនយកថ្នាំវ៉ាក់សាំងដូសទី៣ មកខេត្តបាត់ដំបង ហើយជនជាប់ចោទឱ្យជនរងគ្រោះមកជួបនៅមុខពេទ្យធំ ។ ពេលដែលជនរងគ្រោះមកដល់ ក៏បានជិះម៉ូតូដឹកជនជាប់ចោទទៅហូបបាយនៅភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។ ខណៈពេលដែលកំពុងហូបបាយជនជាប់ចោទក៏បានខ្ចីម៉ូតូម៉ាក PCX (ភីស៊ីអេច) ពណ៌ស ស៊េរីឆ្នាំ២០១៨ ស្លាកលេខ 1AD-6850 ពីជនរងគ្រោះថាទៅយកថ្នាំ ហើយជិះគេចខ្លួនបាត់ ។ បន្ទាប់ពីឆបោកយកម៉ូតូបានហើយ ជននេះបានយកម៉ូតូទៅឱ្យប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] សុឃឿន យកទៅបញ្ចាំ ។ ក្រោយកើតហេតុជនរងគ្រោះបានដាក់ពាក្យបណ្តឹងមកសមត្ថកិច្ច លុះដល់ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២២ ជនជាប់ចោទក៏ត្រូវបាននគរបាលឃាត់ខ្លួនបាន ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ ២៣៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាដំណោះស្រាយលេខ ២៤៨ ដដរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ២៣៨៣ ត.ព្រ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តបាត់ដំបង ។

<u>នាពេលពិភាក្សាដេញដោល</u>

-ជនជាប់ចោទឈ្មោះ [redacted] ពិសិត មានវត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] សុឃឿន អវត្តមាន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ែ អវត្តមាន ។

-សាក្សីឈ្មោះ [redacted] ស្រីស អវត្តមាន ។

-មេធាវី[redacted] មានវត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិត បានឆ្លើយថា: ខ្លួនបានដឹងពីបទចោទប្រកាន់រួចហើយ ។ ខ្លួនស្គាល់ជនរងគ្រោះជាង១ខែ រួចណាត់ជួបគ្នា និងបបួលគ្នាញ៉ាំបាយធម្មតា រួចក៏ខ្ចីម៉ូតូរបស់ជនរងគ្រោះជិះដើរលេង បន្ទាប់មកទៅភ្នំពេញវិញ ។ ខ្លួនស្គាល់ជនរងគ្រោះតាមហ្វេសប៊ុក ។ ដំបូងខ្ចីជិះដើរលេងនៅបាត់ដំបង ដោយសារអត់ប្រាក់ ក៏ជិះទៅភ្នំពេញតែម្តង ហើយខ្លួនយកម៉ូតូនោះទៅបញ្ចាំ តែមិនបានទៅដល់កន្លែងបញ្ចាំទេ មានអ្នកគក់ដេយកទៅបញ្ចាំឱ្យ ដោយសារអត់មានឯកសារ ។ បញ្ចាំបានប្រាក់៧០០ដុល្លារអាម៉េរិក យកទៅទិញថ្នាំលេប និងចាយ ហើយក្រោយមកមិនបានទាក់ទងជនរងគ្រោះវិញទេ ។ ខ្លួនដឹងថាអំពើនេះមានទោស ។ ខ្លួនស្គាល់ឈ្មោះ [redacted] សុឃឿន ត្រូវជាប្តីប្រពន្ធនឹងគ្នា ដោយបានគ្នាជាងបីឆ្នាំ សព្វថ្ងៃគេរស់នៅខេត្តសៀមរាបបែកគ្នា ។ ចំពោះលុយដែលសល់ពីលក់ម៉ូតូ ខ្លួនបានឱ្យឈ្មោះ [redacted] សុឃឿន ខ្លះ គឺឱ្យសម្រាប់ចិញ្ចឹមកូនរបស់ខ្លួន ។ សមត្ថកិច្ចបានឃាត់រូបខ្លួននៅសួន ស ខេង ខេត្តបាត់ដំបង ។ ខ្លួនមានការស្តាយក្រោយ និងដឹងពីកំហុសហើយ ។ នៅពេលដែលសមត្ថកិច្ចឃាត់រូបខ្លួន គឺបានដកហូតទូរស័ព្ទ, ម៉ូតូ និងនាឡិកា ដោយម៉ូតូនោះ គឺបានមកពីលុយសន្សំខ្លះ លុយគេសងខ្លះ និងលុយលក់ម៉ូតូ PCX សល់៣៥០ដុល្លារអាម៉េរិក ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់កិច្ចពិភាក្សាដេញដោលនាពេលសវនាការរួចមក តំណាងអយ្យការប្តឹងសុំតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរដដែល ដោយមានសំអាងហេតុក្នុងដីកាសន្និដ្ឋានស្តាពរនេះស្រាប់ ។ តំណាងអយ្យការពិនិត្យឃើញថា មានភស្តុតាងដែលជនជាប់ចោទបានយកម៉ូតូរបស់ជនរងគ្រោះម៉ាក PCX ស្លាកលេខ 1AD-6850 ដែលជនរងគ្រោះឈ្មោះ [redacted] សាម៉ែ ហើយជនជាប់ចោទក៏បានឆ្លើយសារភាពចំពោះមុខអង្គសវនាការផងដែរ ។ ហេតុនេះ តំណាងអយ្យការស្នើសុំផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានដឹងពីកំហុសដូចការចោទប្រកាន់របស់តំណាងអយ្យការហើយ តែកូនក្តីរបស់ខ្លួនបានប្រព្រឹត្តដោយសារគាត់មានបញ្ហាគ្រួសារច្រើន ។ ម្យ៉ាងនៅពេលកូនក្តីរបស់ខ្លួនជាប់ពន្ធនាគារកន្លងមក គាត់ក៏ពិចារណាដឹងពីកំហុសរបស់គាត់ និងមានការស្តាយក្រោយយ៉ាងខ្លាំង ព្រមទាំងសន្យាថា បើសិនមានឱកាសចេញពីពន្ធនាគារ

នឹងធ្វើខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ។ ហេតុនេះ ខ្លួនស្នើសុំចៅក្រមជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ដោយក្តីអនុគ្រោះ ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **ពិសិត** ៖ ស្នើសុំបន្ធូរបន្ថយទោស ។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលរួចរាល់ហើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>សំអាងហេតុ</u>

ក-តាមដីកាដំណោះស្រាយលេខ ២៤៨ ដជរ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ បានសម្រេចបញ្ជូនឈ្មោះ [redacted] **ពិសិត** ទៅជំនុំជម្រះពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៩១** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] **សុឃឿន** ទៅជំនុំជម្រះពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៩៩** និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

ខ-ពិនិត្យតាមចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនាពេលសវនាការឃើញថាបានសារភាពពីអំពើដែលខ្លួនបានប្រព្រឹត្តអស់ហើយ ដែលការឆ្លើយបែបនេះឃើញថាមានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងជាសោម៉ូតូមួយចំនួន, ស្លាកលេខម៉ូតូមួយចំនួន និងម៉ូតូដែលសមត្ថកិច្ចដកហូតបាននាពេលបង្ក្រាបបទល្មើសជាក់ស្តែង ។ ឆ្លងតាមរយៈចម្លើយទាំងនេះ និងអង្គហេតុជាក់ស្តែងអាចបញ្ជាក់បានថា ជនជាប់ចោទមានទំនាក់ទំនងនឹងជនរងគ្រោះតាមរយៈបណ្តាញសង្គមហ្វេសប៊ុក រួចក៏ណាត់ជួបគ្នាទៅហូបបាយនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បន្ទាប់មកជនជាប់ចោទបានសុំខ្ចីម៉ូតូពីជនរងគ្រោះដោយកុហកថាទៅទទួលបើកថ្មាំ រួចក៏ជិះម៉ូតូរបស់ជនរងគ្រោះគេចខ្លួនទៅភ្នំពេញ ដើម្បីយកម៉ូតូនោះទៅបញ្ចាំ ហើយនៅពេលបញ្ចាំបានប្រាក់ក៏យកឱ្យប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] សុឃឿន ។

គ-ក្រោយពេលប្រព្រឹត្តបទល្មើសរួច ជនជាប់ចោទឈ្មោះ [redacted] សុឃឿន បានគេចខ្លួនបាត់ពីមូលដ្ឋាន ហើយនៅដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួន និងដីកាបង្គាប់ឱ្យនាំខ្លួនលើជននេះរួចហើយ ។ តំណាងអយ្យការបានចេញដីកាកោះហៅជននេះឱ្យចូលរួមសវនាការត្រឹមត្រូវតាមច្បាប់ហើយ តែមិនឃើញជន

នេះមកបង្ហាញខ្លួននាពេលសវនាការ នេះស្តែងឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុ ឃឿន មានចេតនាគេចវេះទោសកំហុសដែលខ្លួនបានប្រព្រឹត្ត ទើបមិនហ៊ានចូលខ្លួនមក ឆ្លើយអះអាង ។ តុលាការកំណត់បានថា ជននេះពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ មែន ។

ឃ-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិត ត្រូវបានច្បាប់បញ្ញត្តថាជាបទ រំលោភលើទំនុកចិត្ត ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

ង-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុឃឿន ត្រូវបានច្បាប់បញ្ញត្តថាជាបទ ទទួលផលចោរកម្ម ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

ច-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិត និងឈ្មោះ [redacted] សុឃឿន បានធ្វើ ឱ្យខូចខាតដល់ទ្រព្យសម្បត្តិអ្នកដទៃ, ប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយ សាធារណៈ និងខុសនឹងច្បាប់រដ្ឋជាធរមាន ។

ឆ-ជនជាប់ចោទឈ្មោះ [redacted] ពិសិត និងឈ្មោះ [redacted] សុឃឿន ជានីតិជនដែលមាន កាយសម្បទាបរិបូរណ៍ ដោយមិនមានសញ្ញាណាមួយបញ្ជាក់ថានាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទទាំងពីរនាក់នេះ មានបញ្ហាវិបល្លាសស្មារតីដែលនាំឱ្យរួចផុតពីការទទួលខុស ត្រូវព្រហ្មទណ្ឌនោះទេ ហើយជនទាំងនេះក៏បានដឹងអំពីផលវិបាកដែលកើតមានឡើង ក្រោយអំពើប្រព្រឹត្តរបស់ខ្លួនដែរ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តបទល្មើសដដែល ។ ហេតុនេះ ឃើញថាជនជាប់ចោទគឺជាជនដែលមានការគិតបានច្បាស់លាស់អំពីអំពើ និងបច្ចុយ ដែលកើតមានឡើងដោយសារអំពើរបស់ខ្លួន ហើយលក្ខខណ្ឌគតិយុត្តតម្រូវឱ្យទទួលខុស ត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ដែលអំពើនេះត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្ម ទណ្ឌដែលចូលជាធរមាន ។

ជ-យល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការមានលក្ខណៈត្រឹម ត្រូវ តុលាការគប្បីពិចារណា ។

ឈ-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពិសិត ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] សុឃឿន ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្ម ទណ្ឌ ។

ញ-តុលាការពិនិត្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិសិត មិនទាន់មានការផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ មុនអំពើល្មើសនោះទេ ។ ម៉្យាងវិញទៀត ជនជាប់ចោទរូបនេះបានសារភាពពីកំហុសរបស់ខ្លួនអស់ហើយមិនធ្វើឱ្យមានការរាំងស្ទះដល់នីតិវិធីរបស់តុលាការ ។ លើសពីនេះ ជនជាប់ចោទឈ្មោះ [redacted] ពិសិត ក្រោយពេលបទល្មើសមានការសោកស្តាយយ៉ាងខ្លាំង និងមានការភ្ញាក់រឭក ព្រមទាំងសន្យាថា នឹងកែប្រែខ្លួនឱ្យក្លាយជាពលរដ្ឋល្អនៅពេលដែលខ្លួនបានចេញពីពន្ធនាគារវិញ។ ហេតុនេះ តុលាការគប្បីផ្តល់ឱ្យជនជាប់ចោទរូបនេះទទួលបាននូវការព្យួរទោសធម្មតា តាមមាត្រា ១០៦ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

ដ-ឈ្មោះ [redacted] សាម៉ែ បានចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានទាមទារសំណងការខូចខាតពីជនជាប់ចោទចំនួន ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាម៉េរិក និងទាមទារសំណងជំងឺចិត្តពីជនជាប់ចោទចំនួន ២.000.000 (ពីរលាន) រៀល ។ ហេតុនេះ តុលាការនឹងលើកយកមកពិនិត្យពិចារណាអំពីសំណងការខូចខាតនេះទៅតាមព្យសនកម្មជាក់ស្តែង ។

ឋ-វត្ថុចាប់យករួមមាន ៖ សោម៉ូតូចំនួន០៣, ប័ណ្ណបើកបរចំនួន០១, ស៊ីមកាតចំនួន ០២ និងស្លាកលេខម៉ូតូចំនួន០៧ (១.ខេមរភូមិន្ទ 1-7778, ២.សៀមរាប 1AB-3473, ៣. ពោធិ៍សាត់ 1G-1374, ៤.ស្វាយរៀង 1K-2669, ៥.ភ្នំពេញ 1AU-2003, ៦.បាត់ដំបង 1C-4803, ៧.បាត់ដំបង 1C-3357), ដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង គឺជាវត្ថុដែលជាកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស ។ ដូច្នេះ តុលាការគប្បីសម្រេចរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ ។

<u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

១-១-ឈ្មោះ [redacted] ពិសិត ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ៥ (ប្រាំ) ខែ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្នថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ ទោសដែលនៅសល់ត្រូវអនុវត្តការព្យួរទោសធម្មតា ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

១-២-ឈ្មោះ [redacted] សុឃឿន ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិផ្កាស្លា សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង

កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ពិសិត និងឈ្មោះ [redacted] សុឃឿន រួមគ្នាសង សំណងការខូចខាតទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ែ ចំនួន ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាម៉េរិក ការទាមទារលើសពីនេះបដិសេធចោល ។

៣-វត្ថុចាប់យករួមមាន ៖ សោម៉ូតូចំនួន០៣, ប័ណ្ណបើកបរចំនួន០១, ស៊ីមកាតចំនួន ០២ និងស្លាកលេខម៉ូតូចំនួន០៧ (១.ខេមរភូមិន្ទ 1-7778, ២.សៀមរាប 1AB-3473, ៣. ពោធិ៍សាត់ 1G-1374, ៤.ស្វាយរៀង 1K-2669, ៥.ភ្នំពេញ 1AU-2003, ៦.បាត់ដំបង 1C-4803, ៧.បាត់ដំបង 1C-3357), ដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ត្រូវរឹបអូស ។

៤-សាលក្រមនេះប្រកាសជាសាធារណៈដោយចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ពិសិត និងកំពាំងមុខជនជាប់ចោទឈ្មោះ [redacted] សុឃឿន និងកំពាំងមុខដើមបណ្តឹង រដ្ឋប្បវេណីឈ្មោះ [redacted] សាម៉ែ ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅបាត់ដំបង ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

ក្រឡាបញ្ជីសវនាការ

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

[redacted]

Scanned with CamScanner